**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**
**រវាង**
**ក្រុមហ៊ុន ជីជីយូ(ខេមបូឌា)ខ្លូស៊ីង ៦.ក**
**និង**
**តំណាងប្រតិភូបុគ្គលិក និង សហជីពការងារកម្មករកម្ពុជាដើម្បីសេរីភាព**
**ប្រចាំរោងចក្រ ជីជីយូ (ខេមបូឌា) ខ្លូស៊ីង ៦.ក**
**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២៣ វេលាម៉ោង ១៣និង០០នាទី នៅក្នុងរោងចក្រ ជីជីយូ(ខេមបូឌា)ខ្លូស៊ីង ៦.ក មានកិច្ចប្រជុំមួយ រវាង តំណាងក្រុមហ៊ុន និង តំណាងកម្មករ សហជីពការងារកម្មករកម្ពុជាដើម្បីសេរីភាព ប្រចាំរោងចក្រ។

នៅក្នុងអង្គប្រជុំនេះ តំណាងនាយកក្រុមហ៊ុនបានជូនដំណឹងដល់បងប្អូនកម្មករ កម្មការិនីទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរោងចក្រថា ពេលនេះរោងចក្រមិនមានការបញ្ជាទិញគ្រប់គ្រាន់ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរការងាររបស់បងប្អូនបុគ្គលិកកម្មករកម្មការិនីចំនួន ១៦៤ នាក់ ក្នុងរយៈពេល២ខែ(ពីរខែ) គឺចាប់ពីថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០២៣ ទៅដល់ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២៣ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ បងប្អូនកម្មករកម្មការិនីបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុនដូចខាងក្រោម៖

១-ក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភក្នុង១ខែចំនួន ...៣០......ដុល្លារ

២-រដ្ឋាភិបាលផ្តល់ប្រាក់ឧបត្ថម្ភក្នុង១ខែចំនួន ...៤០......ដុល្លារ

អង្គប្រជុំបានចប់នៅវេលាម៉ោង១៣និង៤៥នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និង ការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងល្អ។

ថ្ងៃច័ន្ទ ២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ភ្នំពេញ, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៣

**តំណាងប្រតិភូបុគ្គលិក និង តំណាងសហជីព** | **នាយកក្រុមហ៊ុន**

**យ៉ាង ស៊ីនួន** **ម៉ែន សុគុណា** **ឈូក ចិន្តា** **អេក ខុន្នី** **សាន រ័ត្នថាវី**

**ខាត់ ម៉ី** **ប៊ុនថុលដានី** **កន ចាន់លី** **ម៉ែន សុភ័ក្រ** **ពៅ ម៉ាប់**

ក្រុមហ៊ុន ជីជីយូ (ខេមបូឌា) ខ្លូស៊ីង ៦.ក
GCU (CAMBODIA) CLOTHING CO., LTD.
KINGDOM OF CAMBODIA

XU TIANHUA

Scanned with CamScanner